# ឯកឧត្តម ចម ប្រសិទ្ធ ជួបពិភាក្សាការងារជាមួយ ឯកឧត្តម ហ្វាន ង៉ុក ថ អនុប្រធានគណៈកម្មការ ប្រជាជនខេត្ត ហ្វឺ ធាង វេ នៅ ថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០១០

បន្ទាប់ពីចូលរួមនាកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤២ ដែលបានប្រព្រឹត្តទៅនៅទីក្រុងដាណាំងប្រទេសវៀតណាម កាលពីថ្ងៃទី ២២-២៨ រួចមក ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា ក៏បានបន្តដំណើរដឹកនាំគណៈប្រតិភូទៅធ្វើទស្សនៈកិច្ចសិក្សាអំពី វប្បធមិ អរិយធមិ នៅទីក្រុងវេ ខេត្ត ហ្វឺ ធាង វេ ប្រទេសវៀតណាម នៅថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០១០ ផងដែរ ។

ឆ្លៀតឱកាសក្នុងដំណើរទស្សនៈកិច្ច ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ហ្វាន ង៉ុក ថ** (Phan Ngor Tho) អនុប្រធានគណៈកម្មការប្រជាជនខេត្ត ហ្វឺ ធាង វេ ក្នុងគោលបំណងស្វែងយល់អំពីប្រពៃណី វប្បធមិ អរិយធមិ របស់ខេត្តនេះ ។ ជាកិច្ចចាប់ផ្តើមឯកឧត្តម **ហ្វាន ង៉ុក ថ** បានមានប្រសាសន៍ ស្វាគមន៍ចំពោះគណៈប្រតិភូ ជាពិសេសឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងលោកជំទាវ ដែលបានមកធ្វើ ទស្សនៈកិច្ចនៅខេត្ត ហ្វឺ ធាង វេ ដែលខេត្តនេះសំបូរទៅដោយវប្បធមិប្រវត្តិសាស្ត្រ ទាក់ទាញភ្ញៀវទេសចរណ៍ជាច្រើនធ្វើ ទស្សនៈកិច្ច វាំងស្តេចកាលពីសម័យបុរាណរបស់ខេត្ត ។ ឯកឧត្តម **ហ្វាន ង៉ុក ថ** ក៏បានសំណូមពរដល់ឯកឧត្តមទេស រដ្ឋមន្ត្រី ជួយជំរុញឱ្យមានការទំនាក់ទំនងរវាង ខេត្ត ហ្វឺ ធាង វេ និង ខេត្តសៀមរាប ដោយធ្វើយ៉ាងណាឱ្យមានជើងហោះ ហើរផ្ទាល់ទៅវិញទៅមករវាង ខេត្ត ហ្វឺ ធាង វេ និង ខេត្តសៀមរាប ។ ឯកឧត្តមបានបន្តទៀតថា ពិធីមហោស្រព វប្បធមិរបស់ខេត្តនឹងចាប់ធ្វើនៅ ឆ្នាំ ២០១២ ហើយស្នើសុំអញ្ជើញគណៈប្រតិភូកម្ពុជា មកចូលរួមក្នុងពិធីនេះផងដែរ ។

ជាការឆ្លើយតប ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានថ្លែងអំណរអរគុណចំពោះឯកឧត្តម **ហ្វាន ង៉ុក ថ** និងសហការីប្រធានមន្ទីរនានាក្នុងខេត្តដែលបានទទួលស្វាគមន៍ដល់ឯកឧត្តម និងលោកជំទាវ ព្រមទាំងគណៈប្រតិភូ ដោយ សារចំណងសាមគ្គីភាព និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរជាបងប្អូន និងល្អប្រពៃ ។ ឯកឧត្តមទេស រដ្ឋមន្ត្រី ក៏សុំគាំទ្រនិងឯកភាពចំពោះការមានបំណងឱ្យមានជើងហោះហើរផ្ទាល់ទៅវិញទៅមករវាង ខេត្ត ហ្វឺ ធាង វេ និង ខេត្តសៀមរាប ហើយស្នើឱ្យក្រុមហ៊ុនវៀតណាមអ៊ែឡាញ និងក្រុមហ៊ុនកម្ពុជាអង្គរអ៊ែ សហការគ្នាធ្វើយ៉ាងណាឱ្យមាន ជើងហោះហើរនេះយ៉ាងហោចណាស់ ៣ ដងដែរក្នុង១សប្តាហ៍ ដើម្បីពង្រីកវិស័យទេសចរណ៍នៃប្រទេសទាំងពីរ ។ ចំពោះ ការអញ្ជើញឱ្យមកចូលរួមពិធីមហោស្រពវប្បធមិឆ្នាំ ២០១២ នៅក្រុងវេនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី សុំស្នើអោយ អញ្ជើញមកក្រសួងវប្បធមិ និងវិចិត្រសិល្បៈ ដើម្បីដឹកនាំគណៈប្រតិភូមកចូលរួមក្នុងមហោស្រពវប្បធមិនេះ ហើយក៏ជា ការសិក្សាដកបទពិសោធន៍សំរាប់កម្ពុជា ក្នុងការរៀបចំពិធីមហោស្រពវប្បធមិផងដែរ ។ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានស្នើ សុំឱ្យមានការផ្លាស់ប្តូរគណៈប្រតិភូដើម្បីសិក្សាស្វែងយល់ ក៏ដូចជាការដកពិសោធន៍អំពីវប្បធមិ និងអរិយធមិទៅវិញ ទៅមក ។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏ស្នើសុំបង្កើតឱ្យមានការចងសម្ព័ន្ធមេត្រីភាពរវាង ខេត្ត ហ្វឺ ធាង វេ និងខេត្តសៀមរាប ដោយឱ្យឯកឧត្តម **ហ្វាន ង៉ុក ថ** រៀបចំសំណើទៅប្រមុខរដ្ឋាភិបាលដើម្បីសុំការសម្រេច ព្រោះខេត្តទាំងពីរមាន សក្តានុពលទេសចរណ៍ ផ្នែកវប្បធមិប្រវត្តិសាស្ត្រច្រើន ។